ព្រះរាជក្រមលេខ ជស/រកម/០៦ ចុះថ្ងៃ ១២-១១-១៩៩៧ ច្បាប់ស្តីពីការរំលូតកូន

**យើង**
**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**
**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស-រកត-០៨៩៧-១៩៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២ និងអំពី រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**ប្រកាសអោយប្រើ**

ច្បាប់ស្តីពីការរំលូតកូន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ពីបែបបទ និងល័ក្ខខ័ណ្ឌនៃការរំលូតកូន ។

**មាត្រា ២.-**

ការរំលូតកូនគឺជាបញ្ចប់គភ៌តាមវិធីវេជ្ជសាស្ត្រឬតាមវិធីណាមួយ ។

**មាត្រា ៣.-**

ស្ត្រីមានគភ៌ទាំងឡាយអាចសុំអោយគ្រូពេទ្យធ្វើការរំលូតកូនបាន ក្រោយពីបានបំពេញល័ក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ។

**មាត្រា ៤.-**

ក្នុងករណីណាក៏ដោយ ការរំលូតកូនត្រូវតែមានសំណូមពរនិងបានទទួលការយល់ព្រមពីស្ត្រីដែលមានគភ៌ ។

**មាត្រា ៥.-**

មានតែវេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យម ឬឆ្មបមធ្យម ដែលបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាល ទើបអាចធ្វើការរំលូតកូនបាន។

## ជំពូកទី ២
## បែបបទនិងល័ក្ខខ័ណ្ឌ

**មាត្រា ៦.-**

ការរំលូតកូនប្រព្រឹត្តទៅបានតែនៅក្នុងមន្ទីរពេទ្យ មណ្ឌលសុខភាព គ្លីនិក មន្ទីរសម្ភព សាធារណៈឬឯកជនដែលបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាល ។ រាល់សេវាដែលក្រសួងសុខាភិបាលបានអនុញ្ញាតអោយជាកន្លែងធ្វើការរំលូតកូនត្រូវមាន ៖

- លទ្ធភាពបច្ចេកទេសព្យាបាលបន្ទាន់នូវរាល់ផលវិបាកនៃការរំលូតកូន
- មធ្យោបាយបញ្ជូនទៅមន្ទីរពេទ្យ ប្រសិនបើមានការចាំបាច់

**មាត្រា ៧.-**

វេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យមឬឆ្មបមធ្យមដែលមានភារកិច្ចធ្វើការរំលូតកូន ត្រូវពន្យល់ ណែនាំដល់ស្ត្រីដែលមានគភ៌ដែលមកសុំធ្វើការរំលូតកូន ពីគ្រោះថ្នាក់ដែលអាចកើតមានឡើងជាយថាហេតុ បណ្តាលមកពីការរំលូតកូននេះនិងពីផលប្រយោជន៍នៃកិច្ចពន្យារកំណើត។

ប្រសិនបើស្ត្រីដែលមានគភ៌នោះ នៅតែទទូចសុំធ្វើការរំលូតកូន វេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យម ឬឆ្មបមធ្យម អាចធ្វើការរំលូតបាន តែត្រូវស្ថិតនៅក្នុងល័ក្ខខ័ណ្ឌដូចមានចែងនៅក្នុងមាត្រា៨នៃច្បាប់នេះ។

**មាត្រា ៨.-**

ការរំលូតកូនអាចធ្វើទៅបាន ចំពោះតែគភ៌ណាដែលមានអាយុតិចជាង១២សប្តាហ៍។ លើសពី ១២សប្តាហ៍នៃអាយុគភ៌ ការរំលូតកូនអាចទទួលការអនុញ្ញាតបាន លុះតែក្នុងពេលធ្វើរោគវិនិច្ឆ័យ ឃើញថា៖

-គភ៌នោះមានភវនីយភាពមិនលូតលាស់ដូចប្រក្រតីឬបង្កគ្រោះថ្នាក់ដល់ជីវិតម្តាយ

-កូនដែលនឹងកើតមកអាចមានជំងឺធ្ងន់ធ្ងរព្យាបាលពុំជា

-ក្នុងករណីដែលត្រូវគេរំលោភបណ្តាលអោយមានគភ៌ ការរំលូតកូនអាចប្រព្រឹត្តទៅបាន ដោយមិនគិតពីល័ក្ខខ័ណ្ឌដូចមានចែងខាងលើ តែត្រូវមានការស្នើសុំពីសាមីខ្លួន បើស្ត្រីនោះមានអាយុ១៨ ឆ្នាំ ឡើងទៅ ឬការស្នើសុំដោយទទូចពីឪពុកម្តាយឬអាណាព្យាបាល និងសាមីខ្លួន បើស្ត្រីដែលមានគភ៌ មានអាយុតិចជាង ១៨ ឆ្នាំ ។

ការសំរេចនៃបញ្ហានេះ ត្រូវមានការឯកភាពពីក្រុមគ្រូពេទ្យ២ឬ៣រូប រួមទាំងសាមីខ្លួនផង។ ល័ក្ខខ័ណ្ឌបច្ចេកទេសសំរាប់ការអនុវត្តនៃមាត្រានេះត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល។

**មាត្រា ៩.-**

រាល់ឯកសារដែលទាក់ទងទៅនឹងការរំលូតកូន ត្រូវរក្សាទុកជាការសំងាត់ ហើយអាចផ្តល់ទៅសាមីខ្លួន ឬតុលាការ ប្រសិនបើមានការស្នើសុំជាលាយល័ក្ខអក្សរ។

**មាត្រា ១០.-**

សេវាដែលក្រសួងសុខាភិបាលបានអនុញ្ញាតអោយជាកន្លែងធ្វើការរំលូតកូន ដូចមានចែងនៅក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវរៀបចំឯកសារច្បាស់លាស់ស្តីពីករណីរំលូតកូននីមួយៗ ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែមកក្រសួងសុខាភិបាលដោយទៀងទាត់នូវចំនួនរំលូតកូន និងមធ្យោបាយរំលូត ។

## ជំពូកទី ៣
## សមត្ថកិច្ចត្រួតពិនិត្យ

**មាត្រា ១១.-**

ការត្រួតពិនិត្យការរំលូតកូនតាមការកំណត់នៃច្បាប់នេះ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល។

## ជំពូកទី ៤
## ទោសប្បញ្ញត្តិ

**មាត្រា ១២.-**

ជនទាំងឡាយណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៥ឬ៦ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្ម និងទោសទណ្ឌដូចខាងក្រោម ៖

បើជាវេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យមឬជាឆ្មបមធ្យមត្រូវព្រមាន។ ក្នុងករណីមិនរាងចាល ត្រូវបញ្ឈប់ពីមុខងារឬបិទគ្លីនិកឬមន្ទីរសម្ភពនោះ ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដូចចែងខាងក្រោមនេះ។

បើមិនមែនជាវេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យមឬជាឆ្មបមធ្យម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ទៅ១ ឆ្នាំ។

-បើការរំលូតកូននោះបណ្តាលអោយស្ត្រីដែលមានគភ៌មានជំងឺរ៉ាំរ៉ៃឬពិការ ត្រូវផ្តន្ទាទោសពី ១ ឆ្នាំ ទៅ ៥ឆ្នាំ។

-បើការរំលូតកូនបណ្តាលអោយស្ត្រីដែលមានគភ៌មានគ្រោះថ្នាក់ដល់ស្លាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី៥ឆ្នាំ ទៅ១០ឆ្នាំ។

**មាត្រា ១៣.-**

វេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យមឬឆ្មបមធ្យម ដែលបានទទួលការអនុញ្ញាតអោយធ្វើការរំលូតកូន ហើយមិនគោរពលក្ខខ័ណ្ឌណាមួយដូចចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ត្រូវដកហូតយកលិខិតអនុញ្ញាត ដែលចេញអោយដោយក្រសួងសុខាភិបាល ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌ ដែលមានចែងក្នុងមាត្រា១២ នៃច្បាប់នេះ។

លើកលែងតែក្នុងករណីធ្ងន់ធ្ងរដែលស្ត្រីមានគភ៌ត្រូវសង្គ្រោះបន្ទាន់ វិធីវេជ្ជសាស្ត្រនឹងត្រូវបានធានាចំពោះ មុខច្បាប់។

**មាត្រា ១៤.-**

ជនទាំងឡាយណា ដែលបង្ខិតបង្ខំអោយស្ត្រីដែលមានគភ៌ធ្វើការរំលូតកូន ឬធ្វើអោយរលូតកូនដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។ បើការបង្ខិតបង្ខំអោយស្ត្រីដែលមានគភ៌ ធ្វើការរំលូតកូន ឬធ្វើអោយរលូតកូនដោយចេតនានោះបណ្តាលអោយស្ត្រីដែលមានគភ៌មានជំងឺរ៉ាំរ៉ៃពិការ ឬបណ្តាលអោយស្លាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

**មាត្រា ១៥.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៩ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ ៖

-បើជាមន្ត្រីរាជការ ត្រូវទទួលទណ្ឌកម្មតាម មាត្រា ៩០ និង ៩១ នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

-បើមិនមែនជាមន្ត្រីរាជការ ត្រូវបិទគ្លីនិក ឬមន្ទីរសម្ភពឯកជនពី ១ខែ ទៅ ៣ខែ ឬពិន័យជាប្រាក់ពី ប្រាំលានរៀល(៥.០០០.០០០រៀល) ដល់ដប់លានរៀល (១០.០០០.០០០រៀល) ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧
ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់
**ប្រមុខរដ្ឋស្តីទី**
ហត្ថលេខា
**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រីទី១**
ហត្ថលេខា
**អ៊ឹង ហួត**

**នាយករដ្ឋមន្ត្រីទី២**
ហត្ថលេខា
**ហ៊ុន សែន**

បានជំរាបជូន
ឯកឧត្តមនាយករដ្ឋមន្ត្រីទី ១ និងសម្តេចនាយករដ្ឋមន្ត្រីទី ២
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
ហត្ថលេខា
**ឈា ថាំង**